**សុន្ទរកថាបើក**

# សិក្ខាសាលាត្រីភាគីថ្នាក់ជាតិ
# ស្តីពី
# ការលើកកំពស់កិច្ចគាំពារសង្គម និងការបង្កើនមុខរបរ និងការងារ
# ថ្លែងដោយ ឯកឧត្តម អ៊ុំ មាន រដ្ឋលេខាធិការ និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់
# ឯកឧត្តម វង សូត រដ្ឋមន្ត្រី
# ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

**មជ្ឈមណ្ឌលកម្ពុជា-ជប៉ុន ថ្ងៃទី ២៨-២៩ ខែមីនា ២០១២**

**សូមគោរព**

- ឯកឧត្តម **ទី ចំន្ទផល** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានទី១ ក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៏វិស័យកសិកម្ម និងជនបទ
- លោក Helmut Schwarzer ប្រធានទីប្រឹក្សាបច្ចេកទេសគំរោងអង្គការពលកម្មអន្តរជាតិ ខាងការងារ-សហគមន៍អ៊ឺរ៉ុប ប្រចាំនៅទីក្រុងហ្សឺណែវ
- លោក **វ៉ាន់ ស៊ូអៀង** ប្រធានសហព័ន្ធនិយោជក និងសមាគម ពាណិជ្ជកម្មកម្ពុជា
- លោក **វង្ស សុវណ្ណ** តំណាងសហព័ន្ធសហជីព
- ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ
- ភ្ញៀវជាតិ និងអន្តរជាតិ ជាទីរាប់អាន !

ថ្ងៃនេះ ក្នុងនាមថ្នាក់ដឹកនាំក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំមាន កិត្តិយស និងសេចក្តីសោមនស្សរីករាយ ដែលបានចូលរួមក្នុង ពិធីបើកសិក្ខាសាលាត្រីភាគីថ្នាក់ជាតិ ស្តីពីការលើកកំពស់កិច្ចគាំពារសង្គម និងការបង្កើនមុខរបរ និងការងារ ដែលខ្ញុំសូមចាត់ទុកជាសកម្មភាព និងជាកម្មវិធីថ្មីមួយយ៉ាងសំខាន់ក្នុងការឈានទៅកសាងគោលនយោបាយជាតិ ស្តីពីមុខរបរ និងការងារ សម្រាប់កម្ពុជា នាពេលនេះ ។

ទន្ទឹមនឹងនេះដែរ ខ្ញុំសូមស្វាគមន៏យ៉ាងកក់ក្តៅចំពោះវត្តមាន ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលអញ្ជើញមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការនិយោជក អង្គការសហជីព អង្គការ

អន្តរជាតិ ពិសេសមន្ត្រីជាន់ខ្ពស់របស់អង្គការ ILO ទាំងក្នុងស្រុក និងប្រចាំអនុតំបន់ ដែលបានអញ្ជើញចូលរួមក្នុងពិធីនេះ ។

ដូច ឯកឧត្តម លោកជំទាវ លោក លោកស្រី បានជ្រាបហើយថា ក្នុងដំណើរការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក្រោមការដឹកនាំដ៏ប៉ិនប្រសព្វរបស់រាជរដ្ឋាភិបាល ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាជាប្រមុខដឹកនាំ រយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ដោយមានកិច្ចសហការល្អជាមួយក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ក្រសួង ស្ថាប័ន រដ្ឋាភិបាលពាក់ព័ន្ធ សមាគមនិយោជក កម្មករនិយោជិត អង្គការជាតិ និងអន្តរជាតិ ក្រោមជំនួយបច្ចេកទេសរបស់អង្គការ ILO និង ក្រោមជំនួយថវិការបស់សហគមន៍អ៊ឺរ៉ុប យើងសម្រេចបានសមិទ្ធិផលដ៏ ធំធេងមួយចំនួន ដូចជាការរៀបចំ (១)**ឯកសារកម្ពុជា : ឆ្ពោះទៅកាន់យុទ្ធសាស្ត្រជាតិ ស្តីពីមុខរបរ និងការងារ ដើម្បីកាត់បន្ថយភាពក្រីក្រប្រកបដោយចីរភាព (២)ឯកសារស្តីពីការត្រួតពិនិត្យ ឡើងវិញលើការចំណាយផ្នែកកិច្ចគាំពារសង្គម និង(៣)សេចក្តីព្រាងឯកសារស្តីពីកម្ពុជា : ការធ្វើសមាហរណកម្មបញ្ចូលគ្នា រវាងយុទ្ធសាស្ត្រកិច្ចគាំពារសង្គម និងយុទ្ធសាស្ត្រមុខរបរ និងការងារ ។**

ខ្ញុំសូមគូសបញ្ជាក់ថា ឯកសារស្តីពី កម្ពុជា : ការធ្វើសមាហរណកម្មបញ្ចូលគ្នា រវាងយុទ្ធសាស្ត្រកិច្ចគាំពារសង្គម និង យុទ្ធសាស្ត្រមុខរបរ និងការងារនេះ យើងនឹងធ្វើការពិនិត្យ និងពិភាក្សា ក្នុងអំឡុងពេលសិក្ខាសាលារយៈពេល២ថ្ងៃនេះ ដើម្បីរៀបចំផែនការសកម្មភាព និងយុទ្ធសាស្ត្រសំខាន់ៗ សម្រាប់រៀបចំកសាង និងដាក់បញ្ចូលទៅក្នុងគោលនយោបាយជាតិ ស្តីពីមុខរបរ និងការងារដែលយើងសង្ឃឹមថានឹងសម្រេចបានក្នុងអំឡុងពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៥។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី !**

កន្លងមក និងពេលថ្មីៗនេះ ក្រសួងការងារ និងបណ្តុះ បណ្តាលវិជ្ជាជីវៈ បានចុះហត្ថលេខាលើកម្មវិធីការងារសមរម្យសម្រាប់ប្រទេសកម្ពុជា ដែលកម្មវិធីនេះក៏បានបញ្ចូលចំណុច និង គោលដៅសំខាន់ៗទៅក្នុងយុទ្ធសាស្ត្រជាតិគាំពារសង្គមសំរាប់ជនក្រីក្រ និងជនងាយរងគ្រោះនៅកម្ពុជាផងដែរ សំដៅធ្វើយ៉ាងណាឱ្យកម្មវិធីនេះអាចយកទៅប្រើប្រាស់ស្របតាមយុទ្ធសាស្ត្ររបស់ក្រសួង ក៏ដូចជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ។

ផ្អែកលើមូលដ្ឋាននេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានខិតខំជំនះរាល់បញ្ហាប្រឈមនានា និងសម្រេចបាននូវសមិទ្ធិផលធំៗជាច្រើនដូចជា ការធានាបាននូវការការពារកម្លាំងពលកម្ម

ការទទួលបាននូវសិទ្ធិ និង អត្ថប្រយោជន៍ស្របតាមបទប្បញ្ញត្តិច្បាប់ស្តីពីការងារ ច្បាប់ស្តីពីរបបសន្តិសុខសង្គម ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលធានាបាននូវខ្លឹមសារ ៤ យ៉ាង : ចំណេះដឹង សមត្ថភាពជំនាញ ឥរិយាបទការងារ និងសីលធម៌វិជ្ជាជីវៈ ដែលមានលក្ខណៈផ្សារភ្ជាប់ទៅនឹងការអនុវត្តជាក់ស្តែង ។ ម្យ៉ាងទៀត ក្រសួងតែងតែខិតខំពង្រឹងការអនុវត្តច្បាប់ ស្តីពីការងារ ដោយធានាបានលក្ខខណ្ឌការងារល្អប្រសើរ រក្សាបានភាពសុខដុមរមនា ក្នុងទំនាក់ទំនងវិជ្ជាជីវៈ ពង្រឹងសុវត្ថិភាព និងសុខភាពការងារនៅកន្លែងធ្វើការ និងការពារទប់ស្កាត់ពលកម្មកុមារ ព្រមទាំងបានពង្រឹងការអនុវត្តគោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារ ដែលជាឯកសារទី១ នៅក្នុងតំបន់អាស៊ានទៀតផង ។

យោងតាមការស្រាវជ្រាវ បច្ចុប្បន្ននេះយើងមានកម្លាំងពលកម្មប្រមាណ ៧,៤ លាននាក់ នៅក្នុងវ័យចន្លោះពី ១៥ ទៅ ៦៤ ឆ្នាំ ហើយរៀងរាល់ឆ្នាំ យើងមានយុវជនប្រមាណ ២ សែននាក់ឈានចូលដល់វ័យ ដែលចាត់ទុកជាកម្លាំងពលកម្មសកម្ម សំរាប់ឆ្លើយតបនិងតម្រូវការទីផ្សារការងារ ទាំងក្នុង និង ក្រៅប្រទេស ។ ផ្សារភ្ជាប់នឹងបញ្ហានេះ ក៏ទាមទារឱ្យយើងត្រូវបន្តគិតគូរ ឱ្យបានល្អិតល្អន់ លើការបណ្តុះបណ្តាលជំនាញអោយស្របទៅតំរូវការទីផ្សារការងារ ពិសេស ការបង្កើតមុខរបរផ្សេងៗ ដើម្បីឆ្លើយតបនិងការវិវត្តន៍ក្នុងវិស័យឧស្សាហកម្ម កសិឧស្សាហកម្ម និងសេវាកម្មជាដើម ដែលមួយឆ្នាំទៅមួយឆ្នាំមានភាពប្រែប្រួលឥតឈប់ឈរ ទាំងបច្ចេកវិទ្យា និងសមត្ថភាពជំនាញ ។

ទោះបីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រេចបាននូវសមិទ្ធិផលគួរឱ្យកត់សំគាល់ក្តី ពិនិត្យជារួម យើងនៅមានបញ្ហាប្រឈមមួយចំនួន ដែលតម្រូវឱ្យមានការដោះស្រាយឱ្យបានទាន់ពេលវេលា ស្របតាមការអភិវឌ្ឍន៏រីកចំរើននៃសង្គម និងនិន្នាការរួមនៃពិភពលោកបច្ចុប្បន្ន។ នោះគឺភាពខ្វះចន្លោះនៃបទដ្ឋានគតិយុត្ត គោលការណ៍ បទបញ្ញានានា និងគោលនយោបាយ ដែលអាចធ្វើឱ្យប៉ះពាល់ដល់ដំណើរការអនុវត្ត និងដំណើរការអភិវឌ្ឍន៍មុខរបរក្នុងប្រទេស និងការអភិវឌ្ឍន៏ការងារនៅក្រៅប្រទេស។

លទ្ធផលស្តែងចេញពីការទំនាក់ទំនង និង កិច្ចសហការប្រតិបត្តិការល្អរវាងក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ និងស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធជាមួយអង្គការអន្តរជាតិខាងការងារ ILO ក្រោមជំនួយរបស់សហគមន៍អឺរ៉ុប យើងសម្រេចបានសមិទ្ធិផលសំខាន់ៗមួយចំនួនដូចជា :

**-ឯកសារសិក្សាស្តីពី " កម្ពុជា :ឆ្ពោះទៅកាន់យុទ្ធសាស្ត្រជាតិ ស្តីពីមុខរបរ និងការងារ ដើម្បីកាត់បន្ថយភាពក្រីក្រប្រកបដោយចីរភាព"**

**-សេចក្តីព្រាងឯកសារ ស្តីពីការត្រួតពិនិត្យឡើងវិញលើការចំណាយផ្នែកកិច្ចគាំពារសង្គម**

**-សេចក្តីព្រាងឯកសារស្តីពី កម្ពុជា : ការធ្វើសមាហរណកម្មបញ្ចូលគ្នារវាងយុទ្ធសាស្ត្រកិច្ចគាំពារសង្គម និងយុទ្ធសាស្ត្រមុខរបរ និងការងារ** ដែលជាឯកសារដ៏សំខាន់ដើម្បីរៀបចំផែនការសកម្មភាព និងយុទ្ធសាស្ត្រនានាសម្រាប់កសាងគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ និងកិច្ចគាំពារសង្គម សម្រាប់កម្ពុជា ក្នុងការរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ និងភាពងាយរងគ្រោះ ។

ឯកឧត្តម លោកជំទាវ លោក-លោកស្រី !

ខ្ញុំមានសង្ឃឹមយ៉ាងមុតមាំថា ឆ្លងតាមរយៈសិក្ខាសាលាជាតិត្រីភាគីនេះ ពិតជាបានចែករំលែកបទពិសោធន៍ និងផ្តល់មេរៀនចំណេះដឹងផ្សេងទៀតតាមរយៈការផ្តល់បទឧទ្ទេសនាមពីអ្នកឯកទេសដូចដែលមានចែងក្នុងកម្មវិធីសិក្ខាសាលារយៈពេលពីរថ្ងៃនេះស្រាប់ ។

ចំណេះដឹង និងបទពិសោធន៍របស់ឯកឧត្តម លោកជំទាវ លោក លោកស្រី ពិតជាបានរួមចំណែកយ៉ាងពិតប្រាកដក្នុងការអភិវឌ្ឍន៍ផែនការសកម្មភាព និងយុទ្ធសាស្ត្រនានា ដើម្បីឈានទៅកសាងបាននូវគោលនយោបាយជាតិមួយស្តីពីមុខរបរ និងការងារ និងកិច្ចគាំពារសង្គមសម្រាប់កម្ពុជានាពេលអនាគត ។

ជាថ្មីម្តងទៀត ក្នុងនាមថ្នាក់ដឹកនាំក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខ្ញុំសូមថ្លែងអំណរគុណដល់អង្គការពលកម្មអន្តរជាតិខាងការងារ និងសហគមន៍អឺរ៉ុបដែលបានផ្តល់ជំនួយជាបច្ចេកទេស និងថវិកាដល់ក្រសួងរហូតមកទល់ពេលនេះ ។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធិពរ បវរប្រសើរជូនដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិ សូមអោយជួបប្រទះ តែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ ។

សូមប្រកាសបើកអង្គសិក្ខាសាលាចាប់ពីពេលនេះតទៅ ។

**សូមអរគុណ !**